# ព្រឹត្តិបត្រ ស្ដីពីបញ្ហាអាជីវកម្ម

កម្ពុជា

លេខ ១៧ មិថុនា ២០០៩


## មីក្រូហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា : ជំរុញវិស័យនេះឱ្យកាន់តែរីកចំរើនមួយកំរិតទៀត



### ១. សេចក្ដីផ្ដើម

ក្នុងប្រទេសកម្ពុជា សកម្មភាពសេដ្ឋកិច្ចមួយភាគធំពឹងផ្អែកលើសហគ្រាសធុនតូច និងតូចបំផុត (MSMEs) ដែលភាគច្រើនស្ថិតនៅតំបន់ជនបទ។ សហគ្រាសធុនតូច និងតូចបំផុតទាំងនេះមិនបានទទួលសេវាហិរញ្ញវត្ថុពីវិស័យធនាគារទេ ព្រោះថាធនាគារភាគច្រើនផ្ដោតតែលើការបំរើសេវាដល់អាជីវកម្មនៅទីក្រុង។ ដូច្នេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFIs) គឺជាអ្នកផ្ដល់សេវាហិរញ្ញវត្ថុចម្បងសំរាប់សេដ្ឋកិច្ចជនបទ។

សេវាដែលផ្ដល់ដោយ MFIs អាចជួយដល់អ្នកជនបទ ជាពិសេសអ្នកក្រីក្រ ក្នុងការបង្កើនប្រាក់ចំណូល និងទ្រព្យសម្បត្តិរបស់ពួកគេ។ មីក្រូហិរញ្ញវត្ថុក៏ជួយកាត់បន្ថយភាពងាយរងគ្រោះពីស្ថានការណ៍ខាងក្រៅ ដូចជា ជំងឺ និងគ្រោះមហន្តរាយធម្មជាតិនានា ហើយក៏ជួយអភិវឌ្ឍសហគ្រាសធុនតូចទៀតផង។ ដូច្នេះ មីក្រូហិរញ្ញវត្ថុមានតួនាទីសំខាន់ណាស់ក្នុងការអភិវឌ្ឍន៍កម្ពុជា និងកាត់បន្ថយភាពក្រីក្រ ។

វិស័យមីក្រូហិរញ្ញវត្ថុនៅប្រទេសកម្ពុជាមានការរីកចំរើនខ្លាំងជាងគេនៅលើសកលលោក ហើយអន្តរជាតិទទួលស្គាល់ថានេះជារឿងជោគជ័យមួយរបស់កម្ពុជា។ បច្ចុប្បន្ននេះ មាន MFIs ដែលមានអាជ្ញាប័ណ្ណចំនួន ១៨ និងអង្គការក្រៅរដ្ឋាភិបាល (NGOs) ដែលចុះបញ្ជីនៅធនាគារជាតិនៃកម្ពុជាចំនួន ២៦ កំពុងផ្ដល់សេវាមីក្រូហិរញ្ញវត្ថុនៅកម្ពុជា [១]។

វិស័យមីក្រូហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការនាំសេវាមីក្រូហិរញ្ញវត្ថុទៅឱ្យដល់ដៃអ្នកក្រីក្រនៅជនបទ។ វិស័យនេះបានរីកចំរើនយ៉ាងខ្លាំងក្នុងកំឡុងពេលប្រាំឆ្នាំចុងក្រោយនេះ ដែលចំនួនអ្នកខ្ចីប្រាក់បានកើនដល់ ជាង ១ លាននាក់ និងអ្នកសន្សំប្រាក់កើនដល់ជាង ៥២ ម៉ឺននាក់ ក្នុងទូទាំង ២៤ ខេត្ត/ក្រុង។ នៅដំណាច់ឆ្នាំ ២០០៨ ប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុសរុបក្នុងប្រទេសកម្ពុជា បានកើនដល់ជាង ៤៤០ លានដុល្លា ហើយប្រាក់បញ្ញើកើនដល់ជាង ៤៩០ លានដុល្លា។ ពីឆ្នាំ ២០០៦ ដល់ឆ្នាំ ២០០៨ ចំនួនអ្នកខ្ចីប្រាក់បានកើនឡើងយ៉ាងឆាប់រហ័សគឺក្នុងអត្រា ២៣% នៅឆ្នាំ ២០០៦ ២៩% នៅឆ្នាំ ២០០៧ និង ៣១% នៅឆ្នាំ ២០០៨ ហើយប្រាក់កម្ចីបានកើនឡើងលើសពី ៥៥% ក្នុង១ឆ្នាំៗ [២]។

ទោះបីជាវិស័យមីក្រូហិរញ្ញវត្ថុទទួលបានជោគជ័យខ្លាំងក្លាក៏ដោយ ក៏វិស័យនេះនៅតែប្រឈមមុខនឹងបញ្ហាមួយចំនួននៅឡើយដូចជា ក្របខ័ណ្ឌច្បាប់ដែលដាក់កំហិតលើលទ្ធភាពរបស់ MFIs ក្នុងការពង្រីកមុខផលិតផល និងសេវារបស់ខ្លួន និងថ្លៃដើមនៃមូលនិធិខ្ពស់ ដែលរារាំងមិនឱ្យ MFIs សំរេចបាននូវសក្ដានុពលរបស់ខ្លួន ក្នុងការជួយអភិវឌ្ឍប្រទេស ជាពិសេសសេដ្ឋកិច្ចជនបទ។ ដើម្បីសំរេចបាននូវសក្ដានុពលរបស់ខ្លួនក្នុងការបំរើអតិថិជនឱ្យបានកាន់តែច្រើន MFIs ចាំបាច់ត្រូវតែអាចផ្ដល់ផលិតផល និងសេវាឱ្យបានកាន់តែច្រើនមុខ អាចទទួលមូលនិធិជារូបិយប័ណ្ណក្នុងស្រុក និងអាចកាត់បន្ថយថ្លៃដើមលើមូលនិធិ ដែលនេះនឹងធ្វើឱ្យគេអាចបំរើសេវាដល់ជនក្រីក្រនៅជនបទកាន់តែច្រើន ហើយនៅតែរក្សាបាននូវនិរន្តរភាពពាណិជ្ជកម្ម។

ព្រឹត្តិបត្តិស្ដីពីបញ្ហាអាជីវកម្មនេះពិភាក្សាលើចំនុចសំខាន់ពីរ ដែលអាចជួយឱ្យ MFIs សំរេចបាននូវគោលដៅរបស់ខ្លួន: ១- ផលិតផល និងសេវាថ្មីៗដែលអាចជួយវិស័យនេះរីកចំរើន និងស្របពេលជាមួយគ្នា ផ្ដល់ឱ្យអតិថិជននៅតាមតំបន់ជនបទនូវសេវាដែលពួកគេត្រូវការ ។ ២- បរិយាកាសអាជីវកម្ម និងក្របខ័ណ្ឌច្បាប់ដែលកាន់តែល្អប្រសើ ។

រូបទី១: ចំនួនអ្នកខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រាក់កម្ចីសរុបគិតជាលានដុល្លា




ប្រភព: គណនាដោយផ្អែកលើទិន្នន័យពី NBC, CMA, ACELEDA និង MIX

International Finance Corporation
World Bank Group

ព្រឹត្តិប័ត្រស្ដីពីបញ្ហាអាជីវកម្ម ផ្ដល់ជូនលោកអ្នកដែលមានចំណាប់អារម្មណ៍ពីរឿងរ៉ាវទាក់ទិននឹងកិច្ចការអាជីវកម្មនូវសេចក្ដីសង្ខេបខ្លីៗ និងសេចក្ដីវិភាគលើប្រធានបទដែលពាក់ពន្ធ័នឹងបរិយាកាសអាជីវកម្មនៅកម្ពុជា។ ព្រឹត្តិបត្រ័នេះមានរួមបញ្ចូលទាំងមតិ និងយោបល់ផ្សេងៗ របស់មជ្ឈដ្ឋានពាក់ពន្ធ័ផងដែរ។

ព្រឹត្តិបត្រ័នេះ ត្រូវបានបោះពុម្ពឡើងដោយមានការសហការ និង ជួយឧបត្ថម្ភពីកម្មវិធីអភិវឌ្ឍន៍វិស័យឯកជនតំបន់ទន្លេមេគង្គ (MPDF) ដែលជាស្ថាប័នពហុជំនួយគ្រប់គ្រងដោយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ធ្វើការអភិវឌ្ឍន៍វិស័យឯកជន នៅក្នុងប្រទេសវៀតណាម កម្ពុជា និងសាធារណៈរដ្ឋប្រជាធិប្បតេយ្យប្រជាមានិតឡាវ។ ម្ចាស់ជំនួយរួមមាន អូស្រ្តាលី កាណាដា សហគមអឺរ៉ុប ហ្វាំងឡង់ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ អៀរឡង់ ជប៉ុន នូវែលហ្សេឡង់ ហូឡង់ ណរវែស ស៊ុយអែត និងស្វីស។

មតិ ឬយោបល់ទាំងឡាយដែលចុះផ្សាយនៅក្នុងព្រឹត្តិប័ត្រនេះមិនតំណាងឱ្យទស្សនៈជាផ្លូវការរបស់ IFC ទេ វាគ្រាន់តែផ្ដល់ជាព័ត៌មាន យោងបន្ថែមតែប៉ុណ្ណោះ។

---

[១] ធនាគារជាតិនៃកម្ពុជា: មីក្រូហិរញ្ញវត្ថុនៅប្រទេសកម្ពុជា ឆ្នាំ ២០០៧

[២] ទិន្នន័យបានមកពីបណ្ដាញប្តូរព័ត៌មានមីក្រូហិរញ្ញវត្ថុ (MIX) ធនាគារជាតិនៃកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) និងធនាគារអេស៊ីលីដា ។

## ២. ផលិតផល និងសេវាថ្មី

លទ្ធភាពក្នុងការផ្តល់ផលិតផលបានកាន់តែច្រើនមុខ មានសារៈសំខាន់ណាស់ចំពោះ MFIs នាដំណាក់កាលនៃការអភិវឌ្ឍន៍នេះ។ ផលិតផលទាំងនេះមិនគ្រាន់តែផ្តល់អត្ថប្រយោជន៍ដល់អតិថិជនដែលមានស្រាប់ប៉ុណ្ណោះទេ តែវាថែមទាំងជួយដល់ MFIs ក្នុងការទាក់ទាញអតិថិជនថ្មី និងបង្កើនការរីកចំរើនប្រកបដោយនិរន្តរភាពកាន់តែប្រសើរទៀតផង ។

ក្នុងស្ថានភាពទីផ្សារបច្ចុប្បន្ននេះ MFIs មានលទ្ធភាពច្រើន និងចង់ធ្វើការអភិវឌ្ឍន៍សេវាថ្មីៗ តែកង្វះក្របខ័ណ្ឌច្បាប់នៅតែជាឧបសគ្គ។ MFIs លើកឡើងថា ធនាគារជាតិដាក់កំហិតលើពួកគេច្រើនពេកដោយមិនឱ្យពួកគេទទួលប្រាក់បញ្ញើដោយងាយស្រួល ឬផ្តល់ផលិតផល និង សេវាផ្សេងៗទៀតដែលអាចមានតំរូវការខ្ពស់ដូចជាសេវាធានារ៉ាប់រងខ្នាតតូច ភតិសន្យាខ្នាតតូច សេវាផ្ទេរប្រាក់ និងផ្ញើប្រាក់ ។

ការបង្កើតក្របខ័ណ្ឌច្បាប់ដែលអនុញ្ញាតឱ្យMFIs បង្កើនមុខផលិតផល និងសេវារបស់ខ្លួន នឹងធ្វើឱ្យវិស័យនេះរីកចំរើនកាន់តែខ្លាំងថែមទៀត ហើយអាចលើកកំពស់លទ្ធភាពទទួលបាននូវហិរញ្ញប្បទានសំរាប់ពលរដ្ឋកម្ពុជា។

### ២.១ សេវាធានារ៉ាប់រងខ្នាតតូច

ជាទូទៅអ្នកក្រីក្រងាយរងគ្រោះចំពោះហានិភ័យផ្សេងៗ ដែលរួមមានគ្រោះធម្មជាតិ ជំងឺ និងគ្រោះថ្នាក់នានា។ MFIs មានតួនាទីយ៉ាងសំខាន់ក្នុងការកាត់បន្ថយ ឬទប់ស្កាត់ភាពងាយរងគ្រោះទាំងនេះ តាមរយៈការផ្តល់ឥណទានដើម្បីបង្កើនឱកាសរកប្រាក់ចំណូល និងសេវាសន្សំប្រាក់ដើម្បីកសាងធនធានដែលអាចប្រើប្រាស់បាននៅពេលត្រូវការចាំបាច់។ ប៉ុន្តែសេវាប្រាក់សន្សំ និងសេវាឥណទាន មិនគ្រប់គ្រាន់ទេ នៅពេលដែលពួកគេប្រឈមមុខនឹងហានិភ័យដែលបណ្តាលឱ្យមានការបាត់បង់លើសពី អ្វីដែលពួកគេអាចដោះស្រាយបាន។ ពេលនោះ សេវាធានារ៉ាប់រងខ្នាតតូចមានតួនាទីជាអ្នកកាត់បន្ថយហានិភ័យ។ សេវាធានារ៉ាប់រងខ្នាតតូច ការពារគ្រួសារដែលមានប្រាក់ចំណូលទាប ទល់នឹងហានិភ័យ ដោយពួកគេត្រូវបង់ប្រាក់ធានាក្នុងអត្រាមួយដែលសមស្របទៅនឹងលទ្ធភាពដែលហានិភ័យអាចកើតឡើង និងថ្លៃផ្សេងៗទៀតដែលពាក់ព័ន្ធ។

សេវាធានារ៉ាប់រងខ្នាតតូច គឺជាផលិតផលថ្មីសំរាប់កម្ពុជា ហើយបច្ចុប្បន្ននេះ យើងមិនទាន់មានក្របខ័ណ្ឌច្បាប់សំរាប់គ្រប់គ្រងផលិតផលនេះនៅឡើយទេ។ តែទោះជាយ៉ាងនេះក្តី ក៏មានអង្គការខ្លះបានសាកល្បងផ្តល់សេវាធានារ៉ាប់រងខ្នាតតូចសំរាប់ប្រជាជននៅជនបទ និងអ្នកក្រីក្រនៅក្នុងទីក្រុង។ ដើម្បីជួយឱ្យសេវានេះមានការរីកចំរើន ក្របខ័ណ្ឌច្បាប់សមស្របមួយសំរាប់គ្រប់គ្រងប្រតិបត្តិការនេះត្រូវតែបានអនុម័ត ។

### ២.២ ភតិសន្យាខ្នាតតូច

ភតិសន្យាសំដៅដល់ការបង់ប្រាក់ជាប្រចាំដើម្បី មានសិទ្ធប្រើប្រាស់បរិក្ខាដូចជាយានយន្តឬគ្រឿងចក្រដោយមិនចាំបាច់ទិញ។ភតិសន្យាអនុញ្ញាតឱ្យអាជីវកម្មកែលំអ ឬពង្រីកប្រតិបត្តិការរបស់ខ្លួនដោយមិនចាំបាច់ខ្ចីប្រាក់សំរាប់ទិញបរិក្ខាដែលមានតំលៃខ្ពស់ៗឡើយ។ ក្រុមហ៊ុនភតិសន្យា ឬធនាគារមានបរិក្ខាទាំងនោះ ហើយជួលឱ្យអ្នកប្រើប្រាស់។ ប្រតិបត្តិការបែបនេះ មានប្រយោជន៍ណាស់សំរាប់អាជីវកម្មដែលមិនមានទ្រព្យសំរាប់ដាក់បញ្ចាំដើម្បីទទួលបានប្រាក់កម្ចី។ ភតិសន្យា អាចជួយឱ្យអាជីវកម្មរីកចំរើនបានលឿន និងចូលរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច។

ភតិសន្យាខ្នាតតូច មានសារៈប្រយោជន៍ខ្លាំងណាស់ចំពោះសហគ្រាសខ្នាតតូច និងតូចបំផុត និងកសិករដែលមិនអាចទទួលបានប្រាក់កម្ចីពីធនាគារ។ MFIs ស្ថិតក្នុងលក្ខខ័ណ្ឌប្រសើរជាងធនាគារ ក្នុងការផ្តល់សេវាភតិសន្យាខ្នាតតូច ព្រោះពួកគេមានការយល់ដឹងច្រើនជាងធនាគារអំពីប្រតិបត្តិការរបស់អាជីវកម្មខ្នាតតូច និងទីផ្សាររបស់វា។

ប៉ុន្តែមកទល់នឹងពេលនេះ មិនទាន់មានភាពច្បាស់លាស់នៅឡើយទេថាតើ MFIs អាចធ្វើប្រតិបត្តិភតិសន្យាបានឬទេ។ តាមច្បាប់ស្តីពីធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុ ភតិសន្យាត្រូវបានចាត់ទុកថាជាប្រតិបត្តិការរបស់ធនាគារ។ ដូច្នេះហើយស្ថាប័ន ដែលមានអាជ្ញាប័ណ្ណធនាគារអាចផ្តល់សេវាភតិសន្យា។ ហើយវាមិនច្បាស់នៅឡើយទេ ថាតើ MFIs ចាំបាច់ត្រូវតែមានអាជ្ញាប័ណ្ណធនាគារ (ដែលជាលក្ខខណ្ឌមួយដែល MFIs កម្ពុជាពិបាកនឹងទទួលដោយសារវាទាមទារដើមទុនខ្ពស់ពេក) ដើម្បីធ្វើប្រតិបត្តិការភតិសន្យា ឬថា MFIs ដែលជាស្ថាប័នហិរញ្ញវត្ថុមានការត្រួតពិនិត្យត្រឹមត្រូវពីរដ្ឋអាចផ្តល់សេវាភតិសន្យាបាន។ ភាពមិនច្បាស់លាស់នេះ បានរារាំងអាជីវកម្មខ្នាតតូច និងតូចបំផុតនៅជនបទ មិនឱ្យទទួលបានសេវាភតិសន្យា ព្រោះអាជីវកម្មទាំងនេះភាគច្រើននៅក្រៅតំបន់ប្រតិបត្តិការរបស់វិស័យធនាគារ ។

*យើងស្វាគមន៍គំនិតក្នុងការដាក់ភតិសន្យា ឱ្យធ្វើប្រតិបត្តិការក្នុងទីផ្សារកម្ពុជា។ យើងជឿជាក់ថាការដាក់ភតិសន្យាចូលក្នុងទីផ្សារនេះនឹងជួយប្រជាជនឱ្យទទួលបានហិរញ្ញប្បទានកាន់តែច្រើនសំរាប់អាជីវកម្មរបស់គេ។ យើងអាចមើលឃើញថាមានតំរូវការសេវាភតិសន្យា។ ក៏ប៉ុន្តែក្នុងឋានៈជា MFIs យើងមិនត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការភតិសន្យាទេ។*

លោក ហួត អៀងតុង នាយកចាត់ការទូទៅ ហត្ថាកសិករ លីមីតធីត និងប្រធានសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា

### ២.៣ សេវាផ្ញើប្រាក់

នៅប្រទេសកម្ពុជាមានតំរូវការខ្ពស់សំរាប់សេវាផ្ញើប្រាក់។ ការសិក្សាមួយចំនួនបានបង្ហាញថា កម្មករដែលបំរើការងារក្នុងវិស័យកាត់ដេរផ្ញើប្រាក់ប្រហែល ២០ ទៅ ៣០ ដុល្លារអាមេរិកទៅឱ្យក្រុមគ្រួសាររបស់ពួកគេ នៅជនបទ។ ប្រាក់បញ្ញើនេះសរុបទៅមានចំនួនរាប់លានដុល្លាក្នុងមួយខែៗ ហើយកម្មករកាត់ដេរគ្រាន់តែជាផ្នែកមួយនៃទីផ្សារសេវាផ្ញើប្រាក់នៅកម្ពុជាប៉ុណ្ណោះ។

ក្របខ័ណ្ឌច្បាប់នាពេលបច្ចុប្បន្ន អនុញ្ញាតឱ្យតែធនាគារពាណិជ្ជប៉ុណ្ណោះផ្តល់សេវាផ្ញើប្រាក់។ ដោយសារតែតំបន់ប្រតិបត្តិការរបស់ធនាគារពាណិជ្ជនៅមានកំរិត (លើកលែងតែធនាគារអេស៊ីលីដា) វិស័យធនាគារនេះ នៅមានលទ្ធភាពតិចតួចក្នុងការផ្តល់សេវាផ្ញើប្រាក់ដល់ប្រជាពលរដ្ឋនៅជនបទ ហើយកត្តានេះបង្ខំឱ្យអ្នកក្រីក្រផ្ញើប្រាក់ទៅឱ្យក្រុមគ្រួសាររបស់គេតាមរយៈសេវាកម្មក្រៅប្រព័ន្ធដែលមានកំរៃថ្លៃ និងមានហានិភ័យខ្ពស់ ។

*លទ្ធភាពរបស់ប្រជាជនកម្ពុជាក្នុងការផ្ញើប្រាក់ឱ្យគ្រួសាររបស់ពួកគេនៅតំបន់ជនបទនៅមានកំរិត ព្រោះមានតែធនាគារ អេស៊ីលីដាតែមួយគត់ដែលមានតំបន់ប្រតិបត្តិការធំគ្រប់គ្រាន់ ចំណែកឯ MFIs ដែលមានសាខានៅជនបទមិនអាចចូលរួមក្នុងសេវាកម្មផ្ញើប្រាក់ទេ ។ ជាធម្មតា សមាជិកគ្រួសារបញ្ជូនប្រាក់ដោយផ្ទាល់ (ដូចជាតាមរថយន្តឈ្នួល) ដែលជាមធ្យោបាយមួយមានតំលៃខ្ពស់ និងងាយរងគ្រោះពីអំពើឧក្រិដ្ឋ។ ការផ្ទេរប្រាក់ប្រកបដោយសុវត្ថិភាព និងមានតំលៃសមរម្យអាចធ្វើទៅបានដោយអនុញ្ញាតឱ្យធនាគារប្រើប្រាស់បណ្តាញរបស់ MFIs និងដោយប្រើប្រាស់បច្ចេកវិជ្ជាថ្មីដូចជាទូរស័ព្ទដៃជាដើម ដើម្បីបំពេញឱ្យធនាគារដែលគ្មានសាខាគ្រប់គ្រាន់។*

Magarete O. Biallas ប្រធានកម្មវិធីលើកស្ទួយវិស័យហិរញ្ញវត្ថុ តំបន់មេគង្គនៃ IFC

## ៣. បរិយាកាសអាជីវកម្ម និងក្របខ័ណ្ឌច្បាប់

ក្នុងកំឡុងពេល ពីឆ្នាំ ១៩៩៥ ដល់ ២០០០ ឥណទានខ្នាតតូចដែលផ្តល់ដោយអង្គការក្រៅរដ្ឋាភិបាល បានទៅដល់ដៃប្រជាពលរដ្ឋមួយចំនួនធំ ជាពិសេសប្រជាជនក្រីក្រ ។ ការរីកចំរើននេះបានធ្វើឱ្យធនាគារជាតិសំរេចពង្រឹងច្បាប់ និងការត្រួតពិនិត្យលើវិស័យនេះ។ ច្បាប់ស្តីពីធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុ ត្រូវបានដាក់ចេញនៅឆ្នាំ ១៩៩៩ ហើយធនាគាជាតិបានចេញប្រកាសស្តីអំពី MFIs នៅឆ្នាំ ២០០០។ តាមប្រកាសនេះ MFIs

ដែលមានទុនលើសពី ១០០ លានរៀល ត្រូវចុះបញ្ជីនៅធនាគារជាតិ ហើយ MFIs ដែលមានទុនលើសពី ១០០០ លានរៀលត្រូវមានអាជ្ញាប័ណ្ណ ។

មកទល់នឹងពេលនេះ មាន MFIs ១៨ បានទទួលអាជ្ញាប័ណ្ណ ហើយ MFIs ២៦ ផ្សេងទៀតបានចុះបញ្ជីនៅធនាគារជាតិ ។ កត្តានេះបានធ្វើឱ្យសាធារណៈជនមានទំនុកចិត្តកាន់តែច្រើនលើមីក្រូហិរញ្ញវត្ថុ និងបានធ្វើឱ្យវិស័យនេះរីកចំរើនយ៉ាងខ្លាំង ។ MFIs បានទទួលអតិថិជនកាន់តែច្រើនឡើង និងមានការរីកចំរើនគួរឱ្យកត់សំគាល់ក្នុងការកាត់បន្ថយចំណាយក្នុងប្រតិបត្តិការ និងបង្កើនគុណភាពប្រាក់កម្ចីរបស់ខ្លួន ហើយទទួលបាននិរន្តរភាពផ្នែកហិរញ្ញវត្ថុ ។ ទំហំនៃប្រាក់កម្ចីធំជាងមុន គឺជាកត្តាចម្បងមួយទៀតដែលធ្វើឱ្យវិស័យនេះកាន់តែមានប្រសិទ្ធភាពឡើង ។

ការប្រកួតប្រជែងកាន់តែខ្លាំង ការគ្រប់គ្រងហានិភ័យកាន់តែប្រសើរ ប្រតិបត្តិការកាន់តែមានប្រសិទ្ធភាព និងការទទួលបានមូលនិធិក្នុងតំលៃទាបជាងមុន បានធ្វើឱ្យអត្រាការប្រាក់ក្នុងវិស័យមីក្រូហិរញ្ញវត្ថុធ្លាក់ចុះក្នុងកំឡុងពេល ១០ ឆ្នាំចុងក្រោយនេះ (ធ្លាក់ចុះយ៉ាងខ្លាំងនាពេល ៣ ឆ្នាំចុងក្រោយ) ។ អត្រាការប្រាក់ជាមធ្យមលើប្រាក់កម្ចីរបស់ MFIs បានធ្លាក់ចុះពី ៤២% នៅឆ្នាំ ២០០៣ មក ៣២% នៅឆ្នាំ ២០០៦[៣] ។ នៅឆ្នាំ ២០០៧ MFIs ដែលមានអាជ្ញាប័ណ្ណក្នុងប្រទេសកម្ពុជា យកអត្រាការប្រាក់គិតជាមធ្យម ២,៥៤% ក្នុង១ខែ ឬ ២៩,៨២% ក្នុងមួយឆ្នាំ[៤] ។ ទោះបីជាមិនទាន់មានទិន្នន័យផ្លូវការណាមួយ អំពីអត្រាការប្រាក់ក្នុងវិស័យមីក្រូហិរញ្ញវត្ថុនាឆ្នាំ ២០០៨ ក៏ដោយក៏ MFIs មួយចំនួនបានបញ្ជាក់ថា អត្រាការប្រាក់ជាមធ្យមរបស់គេក្នុងឆ្នាំ ២០០៨ គឺប្រហាក់ប្រហែលនឹងឆ្នាំ ២០០៧ ដែរ ។ ទោះបីជាស្ថានភាពនៅឆ្នាំ២០០៩មិនទាន់មានភាពប្រាកដប្រជាដោយសារបរិយាកាសអាជីវកម្មមិនល្អនាពេលបច្ចុប្បន្នក៏ដោយ ក៏លទ្ធភាពរបស់ MFIs ក្នុងការប្រមូលយកប្រាក់បញ្ញើកាន់តែល្អប្រសើរ ។ កត្តានេះអាចជួយពួកគេកាត់បន្ថយថ្លៃដើមលើមូលនិធិ ហើយអត្រាការប្រាក់អាចធ្លាក់ចុះថែមទៀត ។

ពាក់ព័ន្ធទៅនឹងថ្លៃដើមនៃមូលនិធិដែរ គឺការទទួលបានរូបិយប័ណ្ណក្នុងស្រុក ។ MFIs កត់សំគាល់ថា តំរូវការប្រាក់កម្ចីជារូបិយប័ណ្ណក្នុងស្រុកមានច្រើន ប៉ុន្តែពួកគេមិនអាចរកបានមូលនិធិជារូបិយប័ណ្ណក្នុងស្រុកក្នុងអត្រា និងលក្ខខ័ណ្ឌមួយសមស្របទេ ។ ជាលទ្ធផល MFIs មិនអាចផ្តល់ប្រាក់កម្ចីឱ្យបានច្រើនតាមដែលគេអាចធ្វើបាន ដែលកត្តានេះកាត់បន្ថយលទ្ធភាពក្នុងការបំរើប្រជាជនក្រីក្រ ។ លើសពីនេះទៀតការទទួលបានតែមូលនិធិពីបរទេសធ្វើឱ្យ MFIs ប្រឈមនឹងហានិភ័យនៃអត្រាប្តូរប្រាក់នៅពេលដែលគេផ្តល់ប្រាក់កម្ចីជារូបិយប័ណ្ណក្នុងស្រុក ។

ដើម្បីជួយ MFIs ពង្រីកសេវាហិរញ្ញវត្ថុរបស់ខ្លួន រាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យ MFIs ដែលមានអាជ្ញាប័ណ្ណ និងមានដើមទុនគ្រប់គ្រាន់ទទួលយកប្រាក់បញ្ញើ ។

## ៣.១ ការទទួលប្រាក់បញ្ញើ

ប្រកាសស្តីអំពីការផ្តល់អាជ្ញាប័ណ្ណឱ្យ MFIs ទទួលប្រាក់បញ្ញើពីសាធារណៈជន ដែលបានចេញកាលពីខែធ្នូ ឆ្នាំ ២០០៧ ដោយធនាគារជាតិ អនុញ្ញាតឱ្យ MFIs ផ្តល់នូវសេវាដ៏មានសារៈប្រយោជន៏ដល់សាធារណៈជន ។ ប្រកាសនេះក៏នឹងផ្តល់ដល់ MFIs នូវប្រភពមូលនិធិច្រើនជាងមុន និងថោកជាងមុន ជាពិសេសមូលនិធិជារូបិយប័ណ្ណក្នុងស្រុក ហើយកាត់បន្ថយនូវហានិភ័យលើអត្រាប្តូរប្រាក់ បើធៀបនិងការខ្ចីមូលនិធិពីបរទេស ។ ការអនុញ្ញាតឱ្យ MFIs ទទួលយកប្រាក់បញ្ញើ ក្នុងរយៈពេលវែង អាចនាំឱ្យអត្រាការប្រាក់ធ្លាក់ចុះ ។ ក្នុងរយៈពេលខ្លី លទ្ធភាពរបស់ MFIs ក្នុងការទទួលយកប្រាក់បញ្ញើ នឹងបង្កើនលទ្ធភាពទទួលបានហិរញ្ញប្បទានរបស់អាជីវកម្មខ្នាតតូច និងតូចបំផុត ក៏ដូចជាកសិករទូទៅផងដែរ ។

*យើងចេញប្រកាសស្តីអំពីការផ្តល់អាជ្ញាប័ណ្ណឱ្យ MFIs ទទួលប្រាក់បញ្ញើក្នុងគោលបំណងធានាឱ្យបាននូវការគ្រប់គ្រងដ៏រឹងមាំលើ MFIs និងដើម្បីរក្សាបាននូវទំនុកចិត្ត និងការជឿជាក់ពីប្រជាពលរដ្ឋ ព្រោះថាមានតែ MFIs ដែលរឹងមាំទេ ទើបគួរត្រូវបានអនុញ្ញាតឱ្យទទួលយកប្រាក់បញ្ញើ ។*

**លោកជំទាវ តាល់ ណែស៊ីម អគ្គនាយកធនាគារជាតិនៃកម្ពុជា**

ដើម្បីការពារអ្នកសន្សំប្រាក់ និងកសាងទំនុកចិត្តរបស់ពួកគេ ធនាគារជាតិបានប្រកាន់យកភាពតឹងរឹងក្នុងដំណាក់កាលនេះ ។ ប្រកាសនោះ ចែងថា MFIs ណាដែលដាក់ពាក្យសុំអាជ្ញាប័ណ្ណទទួលប្រាក់បញ្ញើត្រូវមានដើមទុនយ៉ាងតិច ២,៥ លានដុល្លាអាមេរិក ដើម្បីការការពារអតិថិជនឱ្យបានល្អ ។ ដោយសារតំរូវការដើមទុនច្រើនបែបនេះមានតែ MFIs តិចតួចប៉ុណ្ណោះអាចបំពេញលក្ខខណ្ឌនេះបាន ដូច្នេះហើយទើបគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួនសំដែងក្តីបារម្ភ ។

*ប្រកាសថ្មីស្តីពីប្រាក់សន្សំមីក្រូហិរញ្ញវត្ថុ គឺជាការវិវត្តន៏ដ៏សំខាន់មួយក្នុងការធ្វើឱ្យស្របច្បាប់ និងប្រាកដប្រជាអំពីឋានៈរបស់ MFIs ដែលមានអាជ្ញាប័ណ្ណទាក់ទងនឹងលទ្ធភាពប្រមែប្រមូលយកប្រាក់សន្សំពីសាធារណៈជន ។*

*នាដំណាក់កាលនេះ ជាពិសេស មូលធនអប្បបរមាខ្ពស់ដែលជាលក្ខខណ្ឌចាំបាច់ក្នុងការទទួលបានអាជ្ញាប័ណ្ណថ្មីដើម្បីប្រមូលប្រាក់បញ្ញើបានធ្វើឱ្យ MFIs ភាគច្រើនមិនដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណថ្មីនោះបាន ។ ក្នុងចំណោម MFIs ដែលមានអាជ្ញាប័ណ្ណ ទាំង ១៨ មានតែគ្រឹះស្ថាន ពីរ ឬ បី ប៉ុណ្ណោះដែលមានលក្ខណៈគ្រប់គ្រាន់ដើម្បីសុំអាជ្ញាប័ណ្ណថ្មីនេះ ។ MFIs តែពីរ ឬ បី នោះមិនអាចបំពេញសេចក្តីត្រូវការនៅទូទាំងប្រទេសបានទេ ។ ដូច្នេះគេត្រូវការកិច្ចខិតខំប្រឹងប្រែងពីសំណាក់រាជរដ្ឋាភិបាល អ្នកផ្តល់ជំនួយនានា និងវិស័យមីក្រូហិរញ្ញវត្ថុដើម្បីធានាឱ្យបានថា ប្រជាជនកម្ពុជាគ្រប់រូបទទួលបានសេវាដាក់ប្រាក់សន្សំប្រកបដោយសុវត្ថិភាព ងាយស្រួល និងដោយមានភាពប្រកួតប្រជែង ។*

**លោក Robert Hickson ជំនាញការខាងប្រាក់សន្សំបញ្ញើមីក្រូហិរញ្ញវត្ថុ និងជាអ្នកប្រឹក្សាយោបល់នៃធនាគារអភិវឌ្ឍន៍អាស៊ី**

បច្ចុប្បន្ននេះ មានតែ MFIs ដែលមានអាជ្ញាប័ណ្ណមួយចំនួនតូចប៉ុណ្ណោះមានដើមទុនគ្រប់គ្រាន់ដើម្បីដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណដើម្បីទទួលប្រាក់បញ្ញើ ហើយមកទល់នឹងពេលនេះមិនទាន់មានការចេញអាជ្ញាប័ណ្ណនេះនៅឡើយ ។ នេះបង្ហាញថា ទោះបីជាមានប្រកាសថ្មីក៏ដោយ ក៏ MFIs នៅតែប្រឈមមុខនឹងបញ្ហាទាក់ទងនឹងការទទួលប្រាក់បញ្ញើ ។ រាជរដ្ឋាភិបាល និងវិស័យមីក្រូហិរញ្ញវត្ថុត្រូវតែសហការគ្នាដើម្បីធានាថា MFIs ភាគច្រើនអាចទទួលផលប្រយោជន៏ពីបទបញ្ញត្តិថ្មីនេះ ហើយក្នុងពេលជាមួយគ្នានោះអាចការពារអ្នកសន្សំប្រាក់បានល្អ ។

*ដូចដែលយើងនិយាយជារឿយៗនៅ CGAP មីក្រូហិរញ្ញវត្ថុនៅកម្ពុជាគឺជារឿងជោគជ័យមួយ ។ តាមពិតទៅ អង្គការ និងភ្នាក់ងារនានានៅកម្ពុជាបានបង្កើត MFIs រឹងមាំ ប្រកបដោយនិរន្តរភាព និងក្របខ័ណ្ឌគោលនយោបាយល្អៗ ដែលក្នុងនោះរាជរដ្ឋាភិបាលមានតួនាទីយ៉ាងសំខាន់ជាអ្នកណែនាំ និងត្រួតពិនិត្យ ។ ដើម្បីបន្តភាពជោគជ័យនេះទៅមុខទៀត គេត្រូវដោះស្រាយបញ្ហាប្រឈមមួយចំនួន ។ ខណៈដែលប្រទេសកម្ពុជាបានប្រឹងប្រែងទាក់ទាញវិនិយោគិនពីអន្តរជាតិ ប្រភពមូលនិធិក្នុងស្រុកមិនទាន់ត្រូវបានទាញយកមកប្រើប្រាស់នៅឡើយ ។ នៅចំពោះមុខ ធនាគារពាណិជ្ជកម្ពុជាចាំបាច់ត្រូវយល់ឃើញថា MFIs គឺជាអតិថិជនដ៏សំខាន់ ហើយធនាគារជាតិគួរតែបន្តសម្របសម្រួលការប្រមូលប្រាក់សន្សំ ជាពិសេសប្រាក់សន្សំជារូបិយប័ណ្ណក្នុងស្រុក ។ សេវាប្រាក់សន្សំគឺជាសេវាដែលប្រជាជនក្រីក្រត្រូវការខ្លាំង ហើយវាអាចជាមធ្យោបាយសំរាប់ MFIs ទទួលបានហិរញ្ញប្បទានដោយខ្លួនឯង ។*

**លោក Eric Duflos ជំនាញការមីក្រូហិរញ្ញវត្ថុ ក្រុមពិគ្រោះយោបល់ដើម្បីជួយអ្នកក្រីក្រ (CGAP)**

[៣] CGAP អ្នកផ្តល់ប្រាក់កំចីថ្មី : តើអ្នកក្រកំពុងតែត្រូវបានគេកេងយកចំណេញដោយអត្រាការប្រាក់មីក្រូឥណទានខ្ពស់? CGAP ខែកុម្ភៈ ឆ្នាំ២០០៩

[៤] ធនាគារជាតិនៃកម្ពុជា មីក្រូហិរញ្ញវត្ថុនៃប្រទេសកម្ពុជា ឆ្នាំ ២០០៧ ។ អត្រាការប្រាក់ដែលបានបង្ហាញជាអត្រាការប្រាក់លើប្រាក់កម្ចីជាប្រាក់ដុល្លាអាមេរិក ។ អត្រាការប្រាក់លើប្រាក់កម្ចីជារូបិយប័ណ្ណផ្សេងទៀតអាចខ្ពស់ជាងនេះ ។ ឧទាហរណ៏ ក្នុងឆ្នាំ ២០០៧ អត្រាការប្រាក់លើប្រាក់កំចីជាប្រាក់រៀល គឺ ៣,៣៦% ក្នុងមួយខែ ឬ ៤៣,៣៨ % ក្នុង១ឆ្នាំ ។

## ៣.២ ការិយាល័យឥណទានឯកជនអាចជួយឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្តល់ប្រាក់កម្ចីល្អជាងមុន

ក្នុងការពិចារណាអំពីការផ្តល់ប្រាក់កម្ចី កង្វះខាតព័ត៌មានឥណទាន គឺជាឧបសគ្គចម្បងសំរាប់ស្ថាប័នផ្តល់ប្រាក់កម្ចី ។ កង្វះខាតព័ត៌មានឥណទាននេះ បង្កើននូវហានិភ័យ និងភាពមិនប្រាកដប្រជា ហើយជាលទ្ធផលប្រសិនបើអ្នកខ្ចីប្រាក់គ្មាន ដី ឬ អាគារ ដែលមានតំលៃខ្ពស់ជាងតំលៃប្រាក់កម្ចីដែលគេស្នើសុំទេ គេនឹងមិនផ្តល់ប្រាក់កម្ចីទេ ។ ទោះបីជាអ្នកខ្ចីប្រាក់ដាក់របស់បញ្ចាំក៏ដោយ ក៏ហានិភ័យនៃការខ្ចីត្រួតគ្នាកើតមាន ហើយចាំបាច់ត្រូវតែបូកបញ្ចូលទៅក្នុងថ្លៃដែលគេត្រូវយកពីអ្នកខ្ចី ។

ដើម្បីបង្កើននូវព័ត៌មានឥណទាន ធនាគារជាតិ ដោយមានជំនួយបច្ចេកទេសពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានបង្កើតប្រព័ន្ធចែករំលែកព័ត៌មានឥណទាន (CIS) ក្នុងឆ្នាំ ២០០៦ ។ CIS នេះត្រូវបានរៀបចំឡើងដើម្បីប្រមូល និងចែករំលែកតែព័ត៌មានអវិជ្ជមាន ដែលបានមកពីធនាគារពាណិជ្ជប៉ុណ្ណោះ (ឧទាហរណ៍ ព័ត៌មានអំពីអ្នកខ្ចីប្រាក់ដែលមិនបានសងប្រាក់ជាដើម) ។ ដូច្នេះព័ត៌មានទាំងនោះនៅមានកំរិត ព្រោះប្រព័ន្ធនោះមិនប្រមូល និងចែករំលែកព័ត៌មានអំពីអ្នកខ្ចីដែលបានបំពេញកាតព្វកិច្ចរបស់ខ្លួនបានត្រឹមត្រូវទេ ។ លើសពីនេះទៀត មានតែធនាគារពាណិជ្ជតែប៉ុណ្ណោះ ដែលអាចក្លាយជាសមាជិករបស់ប្រព័ន្ធនេះបាន MFIs មិនអាចទទួលផលប្រយោជន៍ពីប្រព័ន្ធនោះទេ ។ ដោយសារតែកង្វះព័ត៌មានឥណទាននេះ MFIs អាចផ្តល់ប្រាក់ដល់អតិថិជនដោយមិនបានដឹងថា អតិថិជននោះមានជាប់ជំពាក់បំណុល MFIs ផ្សេងទៀតឡើយ ។ ដូច្នេះហើយអ្នកខ្ចីប្រាក់អាចជំពាក់បំណុលលើសពីសមត្ថភាពសងរបស់គេ ហើយមិនអាចសងបំណុលទាំងនោះបាន ។ ស្ថានភាពនេះអាចកើតមានកាន់តែច្រើន នៅពេលដែលសេដ្ឋកិច្ចមានការធ្លាក់ចុះដូចបច្ចុប្បន្ននេះ ហើយអ្នកខ្ចីប្រាក់បាត់បង់ប្រាក់ចំណូល ។

ការិយាល័យឥណទាន ដែលអាចប្រមែប្រមូលរក្សាទុក និងចែករំលែកទាំងព័ត៌មានអវិជ្ជមាន និងវិជ្ជមានអំពីអ្នកខ្ចី អាចលុបបំបាត់ព័ត៌មានដែលមិនត្រូវគ្នា ហើយស្របពេលជាមួយគ្នានេះ បើសិនជាការិយាល័យឥណទានជាការិយាល័យឯកជន ការិយាល័យនេះអាចផ្តល់ដល់ស្ថាប័នហិរញ្ញវត្ថុនូវសេវាបន្ថែមផ្សេងទៀត ដូចជាសេវាត្រួតពិនិត្យ និងដំណើរការពាក្យស្នើសុំឥណទាន និងដាក់ពិន្ទុឱ្យពាក្យសុំឥណទានទាំងនោះជាដើម ។ សេវាទាំងនេះអាចជួយបង្កើនប្រសិទ្ធភាពនៃប្រតិបត្តិការផ្តល់ប្រាក់កម្ចី និងកាត់បន្ថយថ្លៃដើម ។ការិយាល័យឥណទានឯកជននេះក៏អាចបើកទូលាយដល់ម្ចាស់ឥណទានផ្សេងទៀតក្រៅពីធនាគារ និង MFIs ដូចជាក្រុមហ៊ុនទូរស័ព្ទ ឬក្រុមហ៊ុនផ្តល់សេវាផ្សេងៗទៀតដែលទទួលប្រាក់កំរៃក្រោយពេលផ្តល់សេវាដែរ ។

*ការិយាល័យឥណទានឯកជននៅក្នុងប្រទេសកម្ពុជាមានសារៈសំខាន់ ។ ទោះបីជាបុគ្គលឬអាជីវកម្មត្រូវការហិរញ្ញប្បទានកាន់តែខ្លាំងក៏ដោយ ក៏MFIs មានការលំបាកក្នុងការបំពេញតំរូវការរបស់ពួកគេ ដោយសារកង្វះព័ត៌មានឥណទានដែលគួរឱ្យជឿទុកចិត្ត ដើម្បីជួយធនាគារក្នុងការសំរេចចិត្ត ។*

**លោក ហួត អៀងតុង នាយកចាត់ការទូទៅ ហត្ថាកសិករ លីមីតធីត និងប្រធានសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា**

នៅពេលដែល MFIs ទទួលបានព័ត៌មានឥណទានគ្រប់ជ្រុងជ្រោយ ដែលអាចឱ្យពួកគេកាត់បន្ថយហានិភ័យក្នុងការផ្តល់ប្រាក់កម្ចី ពួកគេអាចផ្តល់ហិរញ្ញប្បទានកាន់តែច្រើនក្នុងអត្រាការប្រាក់ប្រសើជាងមុនដល់អ្នកខ្ចីប្រាក់ដែលមានប្រវត្តិឥណទានល្អ ។

ការិយាល័យព័ត៌មានឥណទាន ដែលផ្តល់ព័ត៌មានគ្រប់ជ្រុងជ្រោយ និងជួយទប់ស្កាត់ការឱ្យប្រាក់កម្ចីជាន់គ្នាច្រើនដល់បុគ្គល ឬ អាជីវកម្មដែលគ្មានលទ្ធភាពសងប្រាក់ទាំងនោះ ។ ដោយសារការិយាល័យឥណទានឯកជន ដែលមានព័ត៌មានគ្រប់ជ្រុងជ្រោយ មានសារៈប្រយោជន៍បែបនេះ គេគួរតែផ្តល់អាទិភាពដល់ការបង្កើត ក្របខ័ណ្ឌច្បាប់ចាំបាច់ដើម្បីអនុញ្ញាតឱ្យ MFIs ទាំងអស់ចែករំលែកព័ត៌មានឥណទាន ។

## ៤. សរុបសេចក្តី

នៅលើពិភពលោក មីក្រូហិរញ្ញវត្ថុមានតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់សេវាហិរញ្ញវត្ថុដល់អ្នកក្រីក្រ ។ នៅប្រទេសកម្ពុជា ការរីកចំរើនដ៏គួរឱ្យចាប់អារម្មណ៍ក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះបញ្ជាក់ថា មីក្រូហិរញ្ញវត្ថុបានទៅដល់ដៃប្រជាជនក្រីក្រមួយភាគធំ ។

ប្រតិបត្តិការកាន់តែមានប្រសិទ្ធភាព រួមជាមួយនឹងប្រាក់ចំណូលដែលខ្ពស់ជាងមុនក្នុងវិស័យមីក្រូហិរញ្ញវត្ថុ បានធ្វើឱ្យវិស័យនេះរីកដុះដាលដល់ទូទាំង ២៤ ខេត្ត/ក្រុង ។ អត្រាការប្រាក់បានធ្លាក់ចុះ ហើយគុណភាពប្រាក់កម្ចីក៏មានភាពល្អប្រសើឡើងផងដែរ ។

កន្លងមករាជរដ្ឋាភិបាលបានផ្តល់ការគាំទ្រដល់ការវិវត្តន៍នេះ ប៉ុន្តែនៅមានការងារជាច្រើនដែលត្រូវធ្វើបន្ថែមទៀត ដើម្បីជួយមីក្រូហិរញ្ញវត្ថុឱ្យសំរេចបានសក្តានុពលរបស់ខ្លួនក្នុងការអភិវឌ្ឍន៍ប្រទេស ជាពិសេសការអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ។ គេគួរតែផ្តល់អាទិភាពដល់ក្របខ័ណ្ឌច្បាប់គ្រប់គ្រង MFIs ដែលរួមមាន :

១-សេវាធានារ៉ាប់រងខ្នាតតូច: ក្របខ័ណ្ឌច្បាប់សំរាប់សេវាធានារ៉ាប់រងខ្នាតតូចត្រូវបានព្រាង ហើយការពិគ្រោះយោបល់ជាមួយអ្នកដែលពាក់ព័ន្ធកំពុងតែត្រូវបានធ្វើឡើង ។ ការអនុមត័អនុក្រឹត្យស្តីពីសេវាធានារ៉ាប់រងខ្នាតតូចឱ្យបានលឿន អាចជួយដល់វិស័យនេះ ដោយការបង្កើតក្របខ័ណ្ឌច្បាស់លាស់ និងជួយអ្នកក្រីក្រ ដោយផ្តល់នូវកិច្ចការពារ និងសេវាថ្មីដល់ពួកគេ ។

២-ភតិសន្យាខ្នាតតូច និងសេវាផ្ញើប្រាក់: ក្របខ័ណ្ឌច្បាប់ដែលអនុញ្ញាតឱ្យ MFIs ផ្តល់នូវផលិតផល និងសេវាថ្មីៗ ដែលរួមមាន ភតិសន្យាខ្នាតតូច និងសេវាផ្ញើប្រាក់ នឹងជួយ MFIs ឱ្យបង្កើនប្រសិទ្ធភាព និងផ្តល់នូវសេវាហិរញ្ញវត្ថុកាន់តែច្រើនដល់ប្រជាជននៅជនបទ ។ ដូចដែលបានរៀបរាប់ខាងលើ MFIs ដែលមានជំនាញខាងអាជីវកម្មខ្នាតតូច និងតូចបំផុត ហើយមានប្រតិបត្តិការគ្របដណ្តប់លើផ្ទៃប្រទេស សក្តិសមបំផុតក្នុងការផ្តល់ផលិតផល និងសេវាទាំងនេះ ។

៣-បញ្ញត្តិស្តីពីសេវាប្រាក់បញ្ញើ: រាជរដ្ឋាភិបាល វិស័យមីក្រូហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍នានា ត្រូវខិតខំបន្ថែមទៀត ក្នុងការកែលំអប្រកាសនេះ ដើម្បីឱ្យប្រកាសនោះជួយ ជាជាងរារាំងការអភិវឌ្ឍន៍វិស័យនោះ ។

៤-រូបិយប័ណ្ណក្នុងស្រុក: គេត្រូវការបទបញ្ញត្តិដើម្បីសំរួលដល់ការបង្កើតទីផ្សារអន្តរធនាគារ និងពង្រឹងនូវវត្តមាននៃចរន្តសាច់ប្រាក់ ដែលជារូបិយប័ណ្ណក្នុងស្រុក ។

៥-ការិយាល័យព័ត៌មានឥណទាន: ក្របខ័ណ្ឌច្បាប់សំរាប់ការិយាល័យព័ត៌មានឥណទានដែលផ្តល់ព័ត៌មានឥណទានគ្រប់ជ្រុងជ្រោយមានភាពចាំបាច់ណាស់ ហើយគួរតែចេញឱ្យបានកាន់តែឆាប់តាមដែលអាចធ្វើបាន ។ ក្របខ័ណ្ឌច្បាប់នេះមិនគ្រាន់តែជួយវិស័យមីក្រូហិរញ្ញវត្ថុប៉ុណ្ណោះទេ តែថែមទាំងជួយដល់វិស័យហិរញ្ញវត្ថុទាំងមូលទៀតផង ។

ក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធនឹង MFIs នឹងបានទទួលផលប្រយោជន៍ពីការកែលំអ ដែលរួមមានការអនុញ្ញាតឱ្យ ស្ថាប័នមីក្រូហិរពាវត្ថុអភិវឌ្ឍ និងពង្រីកមុខផលិតផល និងសេវាកម្មរបស់ខ្លួន ជាពិសេសធ្វើឱ្យកាន់តែងាយស្រួលក្នុងការទទួលប្រាក់បញ្ញើ ផ្តល់សេវាភតិសន្យា និងសេវាផ្ញើប្រាក់ និងអនុញ្ញាតឱ្យទទួលបានព័ត៌មានឥណទានដែលមានលក្ខណៈល្អ ។ ផលប្រយោជន៍ទាំងនេះមិនសំរាប់តែវិស័យមីក្រូហិរញ្ញវត្ថុនិងអ្នកក្រីក្រប៉ុណ្ណោះទេតែក៏សំរាប់សេដ្ឋកិច្ចទាំងមូលផងដែរ ។



រក្សាសិទ្ធ IFC 2009
Publisher: IFC office in Cambodia. 70 Norodom Blvd., Phnom Penh.
Tel: (855)-23-210-922 Fax: (855)-23-215-157
E-mail: Ktouk@ifc.org, Website: www.ifc.org/mekong